# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៏
# ស្តីពី
# ការលើកលែងទិដ្ឋាការចំពោះអ្នកកាន់លិខិតឆ្លងដែនការទូត

*****

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៏ ដែលតទៅនេះហៅកាត់ថា "ភាគី"

ដោយមានបំណងពង្រីកបន្ថែមនូវទំនាក់ទំនងជាមិត្តភាពរវាងប្រទេសទាំងពីរ និង សំរួលដល់ដំណើរទស្សនកិច្ចរបស់អ្នកការទូតនៃប្រទេសទាំងពីរ

បានព្រមព្រៀងគ្នាដូចតទៅ :

## មាត្រា ១

១- ពលរដ្ឋកម្ពុជាកាន់លិខិតឆ្លងដែនការទូតកម្ពុជាដែលមានសុពលភាព ដែលមិនមែនជាសមាជិកនៃគណៈបេសកកម្មការទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅព្រះរាជាណាចក្រថៃឡង់ដ៏ ឬ មិនមែនជាតំណាងអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅអង្គការអន្តរជាតិនានា នៅក្នុងព្រះរាជាណាចក្រថៃឡង់ដ៏ ត្រូវបានអនុញ្ញាតឱ្យចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រថៃឡង់ដ៏ ក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃ ដោយពុំចាំបាច់មានទិដ្ឋាការ ក្នុងករណីជនទាំងនោះ មិនមែនចូលមកដើម្បីស្វែងរកការងារធ្វើណាមួយ ឬ ធ្វើការផ្ទាល់ខ្លួន ឬ ការងារផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រថៃឡង់ដ៏ ។

២- ពលរដ្ឋថៃកាន់លិខិតឆ្លងដែនការទូតថៃដែលមានសុពលភាព ដែលមិនមែនជាសមាជិកនៃគណៈបេសកកម្មការទូត ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រថៃឡង់ដ៏ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឬ

មិនមែនជាតំណាងអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រថៃឡង់ដ៍ ប្រចាំនៅអង្គការអន្តរជាតិនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុញ្ញាតឱ្យចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃ ដោយពុំចាំបាច់មានទិដ្ឋាការ ក្នុងករណីជនទាំងនោះមិនមែនចូលមកដើម្បីស្វែងរកការងារធ្វើណាមួយ ឬ ធ្វើការផ្ទាល់ខ្លួន ឬ ការងារផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ២

១- ពលរដ្ឋកម្ពុជាកាន់លិខិតឆ្លងដែនការទូតកម្ពុជាដែលមានសុពលភាព ដែលបានត្រូវចាត់តាំងឱ្យទៅប្រចាំនៅជាសមាជិកនៃគណៈបេសកកម្មការទូត ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅព្រះរាជាណាចក្រថៃឡង់ដ៍ ឬ ជាតំណាងអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅអង្គការអន្តរជាតិនានា នៅក្នុងព្រះរាជាណាចក្រថៃឡង់ដ៍ ត្រូវបានអនុញ្ញាតឱ្យចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រថៃឡង់ដ៍ ក្នុងរយៈពេលមិនលើសពី៣០ថ្ងៃ ដោយពុំចាំបាច់មានទិដ្ឋាការ ។ រយៈពេលស្នាក់នៅនោះ ដោយយោងតាមសំណើរបស់ស្ថានឯកអគ្គរាជទូតកម្ពុជានៅបាងកក នឹងត្រូវបានពន្យាជូនអ្នកកាន់លិខិតឆ្លងដែនការទូតកម្ពុជានោះ រហូតដល់ពេលចប់អាណត្តិបេសកកម្ម ។

២- ពលរដ្ឋថៃកាន់លិខិតឆ្លងដែនការទូតថៃដែលមានសុពលភាព ដែលបានត្រូវចាត់តាំងឱ្យទៅប្រចាំនៅជាសមាជិកនៃគណៈបេសកកម្មការទូត ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រថៃឡង់ដ៍ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឬ ជាតំណាងអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រថៃឡង់ដ៍ប្រចាំនៅអង្គការអន្តរជាតិនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុញ្ញាតឱ្យចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃ ដោយពុំចាំបាច់មានទិដ្ឋាការ ។ រយៈពេលស្នាក់នៅនោះ ដោយយោងតាមសំណើរបស់ស្ថានឯកអគ្គរាជទូតថៃនៅភ្នំពេញ នឹងត្រូវបានពន្យាជូនអ្នកកាន់លិខិតឆ្លងដែនការទូតកម្ពុជានោះរហូតដល់ពេលចប់អាណត្តិបេសកកម្ម ។

## មាត្រា ៣

ការលើកលែងទិដ្ឋាការ ដូចដែលមានចែងក្នុងមាត្រា ១ ត្រូវរាប់បញ្ចូលទាំងការលើកលែងនៃទិដ្ឋាការចេញ ឬ ទិដ្ឋាការឆ្លងកាត់ ។

NS

## មាត្រា ៤

អ្នកកាន់លិខិតឆ្លងដែនការទូតរបស់ភាគីនិមួយៗ អាចចូលក្នុងទឹកដីនៃភាគីម្ខាងទៀតនៅតាមគ្រប់ច្រកចូលទ្វារព្រំដែន ដែលបើកសំរាប់ឱ្យអ្នកដំណើរអន្តរជាតិធ្វើចរាចរ ។

## មាត្រា ៥

អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនិមួយៗ មានសិទ្ធិបំរុងក្នុងការបដិសេធន៍មិនឱ្យចូល ឬ ក៏បញ្ចប់ការស្នាក់នៅចំពោះពលរដ្ឋណាមួយនៃភាគីម្ខាងទៀត ដែលចាត់ទុកថាជាជនដែលពុំគួរស្វាគមន៍ ឬ ជនដែលត្រូវបានដកហូតបុព្វសិទ្ធិ និង អភយ័ឯកសិទ្ធិជាអ្នកការទូត ។

## មាត្រា ៦

ទាក់ទងដល់បញ្ហាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ឬបញ្ហាសុខមាលភាព ភាគីនិមួយៗមានសិទ្ធិអាចពន្យាពេលអនុវត្តន៍ជាបណ្តោះអាសន្ននូវការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះទាំងស្រុង ឬ ដោយផ្នែក ។ ការ ពន្យាពេលអនុវត្តនេះ នឹងត្រូវបានជូនដំណឹងទៅភាគីម្ខាងទៀត ក្នុងកំឡុងពេល ៣០ថ្ងៃ ជាមុន តាមរយៈផ្លូវទូត ។

## មាត្រា ៧

ភាគីទាំងសងខាងនឹងត្រូវផ្លាស់ប្តូរគំរូលិខិតឆ្លងដែនការទូត តាមរយៈផ្លូវទូត ។ បើសិនជាភាគីណាមួយផ្លាស់ប្តូរលិខិតឆ្លងដែនការទូតរបស់ខ្លួន ភាគីនោះនឹងត្រូវបញ្ជូននូវគំរូលិខិតឆ្លងដែនថ្មីទៅភាគីម្ខាងទៀតអោយបាន៣០ ថ្ងៃ មុនការដាក់ឱ្យប្រើប្រាស់ ។

## មាត្រា ៨

កិច្ចព្រមព្រៀងនេះនឹងអាចផ្លាស់ប្តូរ ឬធ្វើវិសោធនកម្មបើមានការយល់ព្រមតាមរយៈការព្រមព្រៀងជាលាយល័ក្ខអក្សររវាងភាគីទាំងពីរ ។

A

NS

# មាត្រា ៩

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅថ្ងៃទី ៦០ បន្ទាប់ពីថ្ងៃចុះហត្ថលេខា ។ បើភាគីណាមួយមានបំណងបញ្ចប់កិច្ចព្រមព្រៀងនេះ ភាគីនោះត្រូវជូនដំណឹងទៅភាគីម្ខាងទៀតនូវបំណងរបស់ខ្លួនជាលាយលក្ខអក្សរតាមរយៈផ្លូវទូត ហើយកិច្ចព្រមព្រៀងនេះនឹងត្រូវបញ្ចប់សុពលភាពនៅថ្ងៃទី ៩០ បន្ទាប់ពីថ្ងៃជូនដំណឹង ។

ដើម្បីជាសក្ខីភាព ហត្ថលេខីខាងក្រោមនេះ ដោយមានការអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅបាងកក ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ ជាពីរច្បាប់ដើម ជាភាសាខ្មែរ ភាសាថៃ និង ភាសាអង់គ្លេស ដែលអត្ថបទទាំងអស់មានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសនឹងត្រូវយកជាឯកសារគោល ។

ជ. រដ្ឋាភិបាល
នៃព្រះរាជាណាចក្រកម្ពុជា

ហោ ណាំហុង
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីការបរទេស
និង សហប្រតិបត្តិការអន្តរជាតិ

ជ. រដ្ឋាភិបាល
នៃព្រះរាជាណាចក្រថៃឡង់ដ៍

ស៊ូរ៉ាគៀត សាធីរ៉ាថៃ
រដ្ឋមន្ត្រីការបរទេស